# ក្រុមហ៊ុន ឡាស្ទីងវីនន័រ ហ្គាម៉ិន (ខេមបូឌា) ឯ.ក

**恒永达（柬埔寨）制衣有限公司**

LASTINGWINNER GARMENT (CAMBODIA) CO.,LTD

ផ្លូវជាតិលេខ៣ ភូមិ ល្វា ឃុំ អង្គពពេល ស្រុក គងពិសី ខេត្ត កំពង់ស្ពឺ

National road #3 , Lvea Village , Ang Por Pel Commune ,Komg Pisey District , Khompong Speu Province

## កិច្ចព្រមព្រៀងស្តីអំពីព្យួរកិច្ចសន្យាការងារ

## ចាប់ពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ដល់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣

កិច្ចព្រមព្រៀងស្តីអំពីព្យួរការងារចាប់ពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ បានធ្វើឡើងនៅថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៣ រវាងរោងចក្រ ហៅថាភាគី "ក" តំណាងអោយនិយោជក ជាមួយតំណាងកម្មករ សហជីពប្រធានក្រុមប្រចាំរោងចក្រហៅថា ភាគី "ខ"

ភាគីទាំងពីរបានយល់ព្រមលើកិច្ចព្រមព្រៀងមានដូចខាងក្រោម៖

១,ភាគី"ក"ត្រូវព្យួរកិច្ចសន្យាការងារកម្មករមួយចំនួន ចាប់ពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ដល់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

២,ភាគី"ក"និងផ្តល់ចំនួននិងឈ្មោះកម្មករដែលធ្វើការនៅផ្នែកនីមួយៗដែលត្រូវព្យួរការងារ។

៣,ភាគី "ក" ស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២៩៤ នាក់ (ស្រី ២០០នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៤៦៩នាក់ (ស្រី ៣០១នាក់)នៅក្នុងផ្នែកពុកាត់ ចំនួន ៥នាក់ ក្រុមដេរចាប់ពី ក្រុម១ ដល់ ក្រុម៩ ចំនួនសរុប ២៣២នាក់ QC ចំនួន ៣០នាក់ និង ផ្នែកទូទៅសរុបចំនួន ២៧នាក់ ចាប់ពីថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២៣ ដល់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ។

៤,កម្មករដែលព្យួរការងារត្រូវទទួលបានប្រាក់ ១៥ដុល្លារ បូក ៧ដុល្លារ សំរាប់ការស្នាក់នៅ និងធ្វើដំណើរដែលច្បាប់បានកំណត់ សរុប ២២ដុល្លារ កម្មករត្រូវមកទទួលប្រាក់នេះ មុនពេលកម្មករ កម្មការនី ព្យួរកិច្ចសន្យាការងារ គឺត្រូវនឹងថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២៣ បញ្ជាក់៖ បើសិនជាកម្មករដែល បានព្យួរកិច្ចសន្យាការងារ បានបំពេញការងារ បានមួយខែពេញវិញបន្ទាប់ ព្យួរកិច្ចសន្យាការងារ ភាគី"ក" និងបន្ថែម៥០ដុល្លារ ជូនកម្មករដែលបានព្យួរកិច្ចសន្យាការងារ។

៥,កម្មករមិនទទួលបានប្រាក់ឈ្នួលប្រចាំថ្ងៃ ប្រាក់រង្វាន់ ប្រាក់ឧបត្ថម ប្រាក់មុខងារ និងផលប្រយោជន៍ផ្សេងទៀតដែលមិនបានតម្រូវដោយច្បាប់នៅក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ។

៦,ភាគី"ក"ព្យួរកិច្ចការងាររបស់កម្មករដោយរោងចក្រអត់មានការបញ្ជាទិញពីអតិថិជន។

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅចំពោះមុខតំណាងកម្មករ សហជីព និងប្រធានក្រុម បានឯកភាពទាំងសងខាងនិងមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

កំពង់ស្ពឺ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០២៣

| | |
|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងស្នាមមេដៃ |
| ភាគី"ក" | ភាគី"ខ" |

LASTINGWINNER GARMENT (CAMBODIA) CO.,LTD

KINGDOM OF CAMBODIA